ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តតាកែវ

-សំណុំរឿងរដ្ឋប្បវេណីលេខ ៣២៦
ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២៣
-សាលក្រមរដ្ឋប្បវេណីលេខ ០៧ "ឃ"
ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តតាកែវ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០២៤

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តតាកែវ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តតាកែវ

**ដើមចោទ**:

ឈ្មោះ [redacted]សូលីតា ភេទស្រី កើតឆ្នាំ១៩៩២ ជនជាតិខ្មែរ មុខរបរបុគ្គលិកក្រុមហ៊ុន មានទីលំនៅបច្ចុប្បន្ន [redacted]។

**មេធាវីតំណាងដោយអាណត្តិ**

លោក [redacted] អត្តលេខ ៦១៣ , លោក [redacted]អត្តលេខ ២៧៧៩ T និងលោក [redacted]អត្តលេខ ១២០៧ មានការិយាល័យមេធាវី [redacted]។

**ចុងចម្លើយ**:

ឈ្មោះ [redacted]ចាន់ដារ៉ូ ភេទប្រុស កើតឆ្នាំ១៩៩០ សញ្ជាតិខ្មែរ ជនជាតិខ្មែរ មុខរបរអ្នកចាក់ភ្លេង មានទីលំនៅ [redacted]

## អង្គហេតុ និងចំណុចវិវាទ

### ក.ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឲ្យតុលាការចេញ

១.សម្រេចឱ្យដើមចោទឈ្មោះ [redacted]សូលីតា លែងលះគ្នាពីចុងចម្លើយឈ្មោះ [redacted] ចាន់ដារ៉ូ ។

២.អំពីអំណាចមេបាលើកូន៖

២.១.កំណត់យកដើមចោទឈ្មោះ [redacted]សូលីតា ជាអ្នកមានអំណាចមេបាទៅលើកូនស្រីបង្កើតឈ្មោះ [redacted]ចាន់វីរ៉ូម៉ានិជ កើតនៅថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០១៧ រហូតពេលឈានដល់នីតិភាព ។

២.២.បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted]ចាន់ដារ៉ូ ប្រគល់កូនស្រីបង្កើតឈ្មោះ [redacted] ចាន់វីរ៉ូម៉ានិជ ឱ្យដើមចោទឈ្មោះ [redacted]សូលីតា ជាអ្នកគ្រប់គ្រងថែរក្សាចាប់ពីពេលសាលក្រមនេះចូលស្ថាពរ ។



Scanned with CamScanner

៣.សម្រេចឱ្យចុងចម្លើយឈ្មោះ [redacted] ចាន់ដារ៉ូ ប្រគល់ផ្ទះ និងដី ដែលមានសញ្ញាណដូចខាងក្រោម៖

៣.១.វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៥០១០៦-២៦៥៥ ទំហំ ៦២ ម² លេខក្បាលដី ២៦៥៥ ស្ថិតនៅភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ។

៣.២.ឱ្យចុងចម្លើយធ្វើលទ្ធកម្មនៃកម្មសិទ្ធិ ១០០% (មួយរយភាគរយ) នៃទ្រព្យត្រង់ចំណុច៣-១ ។

៤. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ។

## ខ.ដំណើររឿងក្តី និងចំណុចវិវាទ

### ខ.១.ការសង្ខេបអំពីរឿងក្តី

កាលពីអំឡុងឆ្នាំ២០១៦ ដើមចោទឈ្មោះ [redacted] សុនីតា និងចុងចម្លើយឈ្មោះ [redacted] ចាន់ដារ៉ូ បានរៀបការជាមួយគ្នា និងបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍លេខ ០៨ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ របស់សាលាឃុំអង្គាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ នៅអំឡុងពេលរស់នៅជាមួយគ្នា ដើមចោទ និងចុងចម្លើយបង្កើតបានកូនស្រីចំនួន ០១នាក់ ឈ្មោះ [redacted] ចាន់វីរ៉ូមានីជ ព្រមទាំងមានទ្រព្យសម្បត្តិរួម ផ្ទះ និងដី វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៥០១០៦-២៦៥៥ ទំហំ ៦២ ម² លេខ ក្បាលដី ២៦៥៥ ស្ថិតនៅភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ។ ក្រោយមកដើមចោទ និងចុងចម្លើយតែងតែមានរឿងរកាំរកូសរស់នៅមិនចុះសម្រុងនឹងគ្នា ដោយចុងចម្លើយលួចលាក់មានស្រីខាងក្រៅ ហើយចុងចម្លើយបានបែកលំនៅពីដើមចោទកាលពីអំឡុងខែមិថុនា ឆ្នាំ២០២២ រហូតដល់បច្ចុប្បន្ន ។ មូលហេតុទាំងនេះហើយ ដែលធ្វើឱ្យដើមចោទអស់មនោសញ្ចេតនាជាប្តីប្រពន្ធមិនអាចរួមរស់ជាមួយគ្នាតទៅទៀតបានឡើយ ទើបដើមចោទដាក់ពាក្យបណ្តឹងមកតុលាការតែម្តង ។

**ខ.២.អង្គហេតុដែលគ្មានវិវាទ** : គ្មាន ។

**ខ.៣.ចំណុចវិវាទ** : គ្មាន ។

### ខ.៤.ការអះអាងរបស់ភាគី

**-ការអះអាងរបស់របស់ដើមចោទ**

មូលហេតុនៃការទាមទារត្រង់ចំណុចទី១ នេះ ដោយហេតុថា កាលពីអំឡុងឆ្នាំ២០១៦ ខ្ញុំ និងចុងចម្លើយបានរៀបការជាមួយគ្នា និងបានចុះសំបុត្រអាពាហ៍ពិអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ផងដែរ ក្រោយពេលរៀបការរួច ខ្ញុំមានកូនចំនួន ០១ នាក់ឈ្មោះ [redacted] ចាន់វីរ៉ូម៉ានិជ ភេទស្រី កើតថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៧ ។ កន្លងមក ខ្ញុំ និងចុងចម្លើយតែងតែមានរឿងរកាំរកូសនឹងគ្នាដែរ ដោយចុងចម្លើយបានលួចលាក់មានស្រីថ្មី ហើយចុងចម្លើយបានបែកលំនៅជាមួយខ្ញុំតាំងពីអំឡុងឆ្នាំ២០២២ មកដល់បច្ចុប្បន្ន ពោលគឺមានរយៈពេល ០២ ឆ្នាំមកហើយ ។ម្យ៉ាងវិញទៀត ចុងចម្លើយពុំដែលទាក់ទងមកខ្ញុំ និងកូនម្តងណាឡើយ ។ មូលហេតុទាំងនេះហើយ ទើបធ្វើឱ្យអស់មនោសញ្ចេតនាជាប្តីប្រពន្ធនឹងគ្នាតទៅទៀត ទើបខ្ញុំដាក់ពាក្យបណ្តឹងមកតុលាការ ដើម្បីលែងលះពីចុងចម្លើយតែម្តង ។

មូលហេតុនៃការទាមទារត្រង់ចំណុច២ ផ្នែក ២.១ នេះ ដោយហេតុថា ក្រោយពេលរៀបការរួច ខ្ញុំមានកូនចំនួន ០១ នាក់ឈ្មោះ [redacted] ចាន់វីរ៉ូម៉ានិជ ភេទស្រី កើតថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៧ ។ ខ្ញុំចង់មើលថែកូន ហើយខ្ញុំក៏មានប្រាក់



Scanned with CamScanner

ចំណូលប្រចាំខែផងដែរ ដោយ ០១ ខែ ចំនួន ៦០០ $ (ប្រាំមួយរយ) ដុល្លារអាមេរិកខ្ញុំគិតថា ខ្ញុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងផ្តល់ការសិក្សាឱ្យកូនបានល្អប្រសើរ និងអប់រំកូនឱ្យក្លាយជាពលរដ្ឋល្អក្នុងសង្គម ។ ម្យ៉ាងវិញទៀតចុងចម្លើយមិនមានទីលំនៅច្បាស់លាស់នោះទេ ។ សព្វថ្ងៃកូនរស់នៅជាមួយខ្ញុំ ហើយគាត់អាយុ ៦ឆ្នាំហើយ ។

មូលហេតុនៃការទាមទារត្រង់ចំណុច៣ ផ្នែក ៣.១ នេះ ដោយហេតុថា ផ្ទះនេះ ខ្ញុំ និងចុងចម្លើយរួមគ្នាតាំងពីឆ្នាំ២០១៩ មក ដោយបង់រំលោះរយៈពេល ២២ ឆ្នាំ ទើបដាច់ ។ សព្វថ្ងៃនេះ ខ្ញុំបង់រំលោះតែម្នាក់ឯងបានបង់រយៈពេល ៥ឆ្នាំមកហើយ ។

ចំពោះការទាមទារត្រង់ចំណុច២ ផ្នែក ២.១ និងចំណុចទី៣ ផ្នែក ៣.២ នេះ ខ្ញុំឈប់ទាមទារទៀតហើយ និងសុំឱ្យតុលាការពុំបាច់សម្រេចនោះទេ ។

**-ការអះអាងរបស់របស់ចុងចម្លើយ**

ចុងចម្លើយឈ្មោះ **ញឹម ចាន់ដារ៉ូ:** អវត្តមាន ។

## សំអាងហេតុ

១.ផ្អែកតាមកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងកំណត់ហេតុនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទបានសុំលែងលះពីចុងចម្លើយ ដោយហេតុថា ខ្លួនរស់នៅមិនចុះសម្រុងនឹងគ្នា ហើយចុងចម្លើយបានបែកលំនៅពីខ្លួនតាំងពីអំឡុងខែមិថុនា ឆ្នាំ២០២២ មកម្ល៉េះ ទើបធ្វើឱ្យខ្លួនអស់មនោសញ្ចេតនាជាប្តីប្រពន្ធតទៅទៀត ។

ក្រោយពីបានពិនិត្យភស្តុតាងនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់រួចមក តុលាការពិនិត្យឃើញថា ដើមចោទ និងចុងចម្លើយពិតជាបានរៀបការ ព្រមទាំងបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១០ ប្រាកដមែន ។ ក្រោយពីរៀបអាពាហ៍ពិពាហ៍ គឺបានរស់នៅបែកគ្នាជាបន្តបន្ទាប់តាំងពីអំឡុងខែមិថុនា ឆ្នាំ២០២២ រហូតមកដល់បច្ចុប្បន្ន ពោលគឺមានរយៈពេលជាង ១ឆ្នាំ មកហើយ ដែលផ្ទុយនឹងគោលបំណងនៃអាពាហ៍ពិពាហ៍ប្រាកដមែន ។ ដូចនេះ គប្បីតុលាការសម្រេចឱ្យលែងលះតាមបញ្ញត្តិមាត្រា៩៧៨ នៃក្រមរដ្ឋប្បវេណី ។

២.ផ្អែកតាមកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងកំណត់ហេតុនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទបានសុំសិទ្ធិមេបាលើកូនឈ្មោះ [redacted] **ចាន់វីរ៉ូម៉ានិជ** ដោយហេតុថា ខ្លួនចង់មើលថែកូន ហើយខ្លួនក៏មានពេលវេលាមើលថែកូន និងលទ្ធភាពក្នុងការផ្តល់ការសិក្សាឱ្យកូនបានល្អប្រសើរផងដែរ ។

ក្រោយពីបានពិនិសត្យភស្តុតាងនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់រួចមក តុលាការពិនិត្យឃើញថា ក្នុងការរស់នៅជាមួយគ្នា ដើមចោទ និងចុងចម្លើយមានកូន ០១ នាក់ ឈ្មោះ [redacted] **ចាន់វីរ៉ូម៉ានិជ** ភេទប្រុស កើតថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៧ ប្រាកដមែន ហើយដើមចោទសុំសិទ្ធិអំណាចមេបាលើកូន ។ ដូចនេះ គប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទតាមបញ្ញត្តិមាត្រា១០៣៧ នៃក្រមរដ្ឋប្បវេណី ។

៣.ផ្អែកតាមកំណត់ហេតុនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងកំណត់ហេតុនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដើមចោទសុំសិទ្ធិគ្រប់គ្រងផ្ទះ និងដី ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៥០១០៦-២៦៥៥ (ដី និងផ្ទះ) ទំហំ ៦២ ម² លេខ ក្បាលដី ២៦៥៥ ស្ថិតនៅភូមិថ្នា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ របស់មន្ទីរ



Scanned with CamScanner

រៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ ។

ក្រោយពីបានពិនិត្យភស្តុតាងនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់រួចមក តុលាការពិនិត្យឃើញថា ផ្ទះ និងដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៥០១០៦-២៦៥៥ ជាទ្រព្យរួមក៏ពិតមែន ប៉ុន្តែជាទ្រព្យរួមដែលជាប់បន្ទុក (បំណុល) ពោល គឺដើមចោទ និងចុងចម្លើយកំពុងតែបង់រំលោះ ដែលមានរយៈពេល ២២ ឆ្នាំ ហើយជាក់ស្តែងដើមចោទបង់បានរយៈពេល ៥ ឆ្នាំ នៅសល់ ១៧ ឆ្នាំទៀត មានន័យថា ផ្ទះ និងដី ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៥០១០៦-២៦៥៥ ទំហំ ៦២ ម² លេខ ក្បាលដី ២៦៥៥ មានទីតាំងស្ថិតនៅភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដើមចោទ និងចុងចម្លើយពុំទាន់ក្លាយជាម្ចាស់កម្មសិទ្ធិករពេញលេញនៅឡើយ។ ដូចនេះគប្បីតុលាការសម្រេចច្រានចោលការទាមទាររបស់ដើមចោទ ។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់គូភាគី គប្បីតុលាការសម្រេចតាមបញ្ញតិមាត្រា៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**<u>សេចក្តីសម្រេចបញ្ចប់</u>**

១.ឲ្យដើមចោទឈ្មោះ [redacted] **សុនីតា** និងចុងចម្លើយឈ្មោះ [redacted] **ចាន់ដារ៉ូ** លែងលះពីគ្នា ។

២.កំណត់យកឈ្មោះ [redacted] **សុនីតា** ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] **ចាន់ទីរ៉ូនិជ** ភេទស្រី កើតថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៧ ។

៣.ការទាមទារឱ្យចុងចម្លើយប្រគល់ផ្ទះ និងដី ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ១២០៥០១០៦-២៦៥៥ ទំហំ ៦២ ម² លេខ ក្បាលដី ២៦៥៥ ស្ថិតនៅភូមិទ្វា សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ របស់ដើមចោទ ត្រូវច្រានចោល។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ ។

សាលក្រមនេះ ត្រូវបានប្រកាសនៅសវនាការជាសាធារណៈនៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤ ។ ក្នុងករណីដែលប្តឹងឧទ្ធរណ៍ត្រូវធ្វើឡើងក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

---

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃចន្ទ ២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ខេត្តតាកែវ,ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]